**សេចក្តីប្រកាសព័ត៌មាន**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

ថ្ងៃទី ២៩ សីហា ឆ្នាំ២០១៩

# ពិធីសម្ពោធដាក់ឲ្យដំណើរការគម្រោង «ពន្លកចំណេះ» ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា

ថ្ងៃនេះ ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា លោកជំទាវ *អេនជេលឡា ខកខីរ៉េន* បានចូលរួមពិធីសម្ពោធដាក់ឲ្យដំណើរការគម្រោងថ្មីមួយ ដើម្បីលើកកម្ពស់វិស័យសិក្សាស្រាវជ្រាវប្រកបដោយគុណភាព និងការបង្កើតគោលនយោបាយដោយផ្អែកលើភស្តុតាងនៅកម្ពុជា។

*ពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍ* គឺជាគម្រោងមួយដែលមានរយៈពេល៣ឆ្នាំ (២០១៩~២០២២) និងមានទឹកប្រាក់ ២,៩ លានដុល្លារអូស្ត្រាលី។ គម្រោងនេះ ផ្តួចផ្តើមឡើងក្នុងគោលបំណងរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នសិក្សាស្រាវជ្រាវនានា ប្រកបដោយគុណភាព។ គម្រោងដដែលនេះ ក៏មានគោលបំណងជំរុញឲ្យមានការប្រើប្រាស់កិច្ចការស្រាវជ្រាវ ដើម្បីជូនដំណឹងដល់ការវិភាគគោលនយោបាយសាធារណៈ និងការសន្ទនានៅកម្ពុជាផងដែរ។

គម្រោង ដែលអនុវត្តដោយអង្គការមូលនិធិអាស៊ីនេះ នឹងជំរុញការពិភាក្សាគោលនយោបាយដោយផ្អែកលើភស្តុតាងរវាងអ្នកបង្កើតគោលនយោបាយ ស្ថាប័នសិក្សាស្រាវជ្រាវ សាកលវិទ្យាល័យ ក្រុមហ៊ុនប្រឹក្សាស្រាវជ្រាវ និងអង្គការក្រៅរដ្ឋាភិបាល។

ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា លោកជំទាវ *អេនជេលឡា ខកខីរ៉េន* មានប្រសាសន៍ថា៖ «កម្ពុជា រំពឹងចង់ក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ត្រឹមឆ្នាំ២០៥០។ ដើម្បីឈានដល់គោលដៅនេះ ការប្រើប្រាស់ភស្តុតាងជាក់លាក់ច្បាស់លាស់ ពិតជាមានសារៈសំខាន់ដើម្បីពន្យល់អំពីការសម្រេចចិត្តរបស់អ្នកបង្កើតគោលនយោបាយនាពេលខាងមុខ។ គម្រោង «ពន្លកចំណេះ»

នឹងជួយសង្គមស៊ីវិល និងរដ្ឋាភិបាលត្រៀមខ្លួនសម្រាប់បញ្ហាប្រឈមស្មុគស្មាញកាន់តែច្រើនឡើង ដែលកម្ពុជានឹងជួបប្រទះ ស្របពេលដែលសម្បត្តិជាតិមានការកើនឡើង»។

«ពន្លកចំណេះ» នឹងបំពេញបន្ថែមទំនាក់ទំនងដ៏យូរអង្វែងនៃការអភិវឌ្ឍគោលនយោបាយរវាងស្ថាប័នអូស្ត្រាលី និងកម្ពុជា ចំពោះកំណែទម្រង់វិស័យកសិកម្ម សុខាភិបាល ពាណិជ្ជកម្ម និងសេដ្ឋកិច្ច។

«ពន្លកចំណេះ» ក៏នឹងជួយកសាងទំនាក់ទំនងរវាងស្ថាប័នកម្ពុជា និងស្ថាប័នស្រាវជ្រាវនានាក្នុងបណ្តាប្រទេសអាស៊ាន និងអូស្ត្រាលីថែមទៀតផង។

នៅឯពិធីសម្ពោធថ្ងៃនេះ ក៏មានការប្រកាសអំពីឱកាសដាក់សំណើថវិកាចំនួនពីរសម្រាប់ស្ថាប័នវិស័យចំណេះដឹង។ ស្ថាប័នដែលមានចំណាប់អារម្មណ៍ សូមចូលទៅកាន់ www.policypulse.org សម្រាប់ព័ត៌មានលម្អិត។

ព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ Australian.Embassy.Cambodia@dfat.gov.au